00364770

E72/2

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 21 / 08 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | |
|---|---|
| **សំណុំរឿងព្រហ្មទណ្ឌលេខ៖** | ០០១/១៨-០៧-២០០៧-**អវតក/អជសដ** |
| **ដាក់ទៅ:** | អង្គជំនុំជម្រះសាលាដំបូង |
| **ថ្ងៃដាក់:** | ១៩/០៨/០៩ |
| **ភាគីអ្នកដាក់:** | មេធាវីលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច |
| **ភាសាដើម:** | បារាំង |
| **ប្រភេទឯកសារ:** | សាធារណៈ |

---

# ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើសុំតែមួយគត់របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ និងក្រុម ២ ដែលស្នើសុំឲ្យអង្គជំនុំជម្រះសម្រេចលើលក្ខណៈសម្បត្តិរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើកំណត់សម្គាល់លើសំណួរ ដែលពាក់ព័ន្ធទៅនឹងការកំណត់អំពីទោស

---

**<u>អ្នកដាក់ឯកសារ:</u>**

**<u>សហមេធាវីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច</u>**

មេធាវី **ការ សាវុត្ថ**

មេធាវី **François ROUX**

មេធាវី **Marie-Paule CANIZARES**

**<u>ចម្លងជូន:</u>**

**<u>ការិយាល័យសហព្រះរាជអាជ្ញា</u>**

លោកស្រី **ជា លាង**

លោក **Robert PETIT**

**<u>អ្នកទទួលឯកសារ:</u>**

**<u>អង្គជំនុំជម្រះសាលាដំបូង</u>**

ចៅក្រម **និល ណុន** ជាប្រធាន

លោកស្រីចៅក្រម **Silvia CARTWRIGHT**

ចៅក្រម **យ៉ា សុខន**

ចៅក្រម **Jean-Marc LAVERGNE**

ចៅក្រម **ធូ មណី**

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 19 / 08 / 2009
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

00364771

E 72/2

[001/18-07-2007-អវតក/អជសដ]

**<u>ចម្លងជូន:</u>**

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

មេធាវី **គង់ ពិសី**

មេធាវី **ហុង គឹមសួន**

មេធាវី **យុង ផានិត**

មេធាវី **គីម ម៉េងឃី**

មេធាវី **ម៉ុច សុវណ្ណារី**

មេធាវី Silke STUDZINSKY

មេធាវី Martine JACQUIN

មេធាវី Philippe CANNONE

មេធាវី **ទី ស្រីនណា**

មេធាវី Pierre Olivier SUR

មេធាវី Alain WERNER

មេធាវី Brianne McGONIGLE

មេធាវី Annie DELAHAIE

មេធាវី Elizabeth RABESANDRATANA

មេធាវី Karim KHAN

E/72/2

[001/18-07-2007-អវតក/អជសដ]

## សូមគោរពជូនអង្គជំនុំជម្រះសាលាដំបូង

### I. រំលឹកពីអង្គហេតុនិងកម្មវត្ថុនៃចម្លើយតប

១. តាំងពីដំណាក់កាលនៃសវនាការបឋម មេធាវីការពារបានប្រឆាំងដាច់ខាតទៅនឹងលទ្ធភាពដែលថាដើមបណ្ដឹងរដ្ឋប្បវេណីអាចមានសិទ្ធិស្នើអំពីការដាក់ទោស ក្នុងរឿងក្ដីលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ហើយមេធាវីការពារក្ដីក៏បានលើកឡើងផងដែរនូវហេតុផលនានាដែលជម្រុញឱ្យមានការប្រឆាំងនេះ [1]។

២. នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៩ និងថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ មេធាវីការពារក្ដីបានទទួលនូវលិខិតជូនដំណឹងជាភាសាខ្មែរ និងជាភាសាបារាំង ស្ដីពី "សំណើសុំតែមួយគត់របស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ១ និងក្រុម ២ ដែលស្នើសុំឱ្យអង្គជំនុំជម្រះសម្រេចលើលក្ខណៈសម្បត្តិ របស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការធ្វើកំណត់សម្គាល់លើសំណួរ ដែលពាក់ព័ន្ធទៅនឹងការកំណត់អំពីទោស" [2]។

៣. តាមរយៈចម្លើយតបនេះ មេធាវីការពារក្ដីសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូងមេត្តាបដិសេធចោលនូវសំណើសុំរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីដោយអនុគ្រោះ។

---

[1] សូមពិនិត្យមើលឯកសារប្រតិចារិកនៃសវនាការជាសាធារណៈ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩, E1/4.1, ទំព័រទី ៧ បន្ទាត់ទី២១ និងបន្តបន្ទាប់។ សូមពិនិត្យមើល *"ចម្លើយតបរបស់ក្រុមមេធាវីការពារទៅនឹងបញ្ជីឈ្មោះសាក្សី និងឯកសារដែលដាក់ដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ១"* ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩ (E28/1 និង E28/2) និងសូមពិនិត្យមើល *"សេចក្ដីបញ្ជាក់របស់ក្រុមមេធាវីការពារពាក់ព័ន្ធទៅនឹងបញ្ជីឈ្មោះសាក្សីរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ១"* (E28/3)។ សូមពិនិត្យមើលផងដែរនូវឯកសារប្រតិចារិកនៃសវនាការជាសាធារណៈ ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ (E1/7.1), ទំព័រទី ៥ បន្ទាត់ទី១១ និងបន្តបន្ទាប់។

[2] ឯកសារលេខ E72

## II. ឧទ្ទិករណ៍របស់មេធាវីការពារក្ដី

៤. មេធាវីការពារនូវតែរក្សាជំហរដែលថា បទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងវិធានផ្ទៃក្នុងនៃ អវតក បានចែងយ៉ាងច្បាស់ថារាល់បញ្ហាដែលពាក់ព័ន្ធជាមួយការកំណត់ទោស គឺជាផ្នែកនៃបណ្ដឹងអាជ្ញា ដូច្នេះបញ្ហានេះវាស្ថិតក្នុងសមត្ថកិច្ចផ្ដាច់មុខរបស់សហព្រះរាជអាជ្ញា [3]។ ក្នុងករណីនេះ វិធាន ១០៥ នៃវិធានផ្ទៃក្នុងនៃ អវតក មិនមានលក្ខណៈច្បាស់លាស់ ពីព្រោះថាវិធាននេះបានអនុញ្ញាតិឲ្យដើមបណ្ដឹងរដ្ឋប្បវេណីអាចធ្វើបណ្ដឹងសារទុក្ខ "*ចំពោះផលប្រយោជន៍រដ្ឋប្បវេណីបានតែក្នុងករណីដែលមានបណ្ដឹងសារទុក្ខរបស់សហព្រះរាជអាជ្ញាក្នុងរឿងនោះតែប៉ុណ្ណោះ*"។

៥. ម្យ៉ាងទៀត មេធាវីការពារក្ដីសូមបញ្ជាក់ផងដែរថា គោលការណ៍ដែលថា មានតែអយ្យការតែមួយគត់ដែលមានសិទ្ធិធ្វើកំណត់សម្គាល់អំពីទោសក្នុងរឿងក្ដី តាមប្រព័ន្ធ រ៉ូម៉ាំង-អាល្លឺម៉ង់ (ឬហៅថាប្រព័ន្ធ "Civil law" ) នោះ គោលការណ៍នេះត្រូវបានលើកឡើងយ៉ាងជាក់ច្បាស់នៅក្នុងសៀវភៅជាច្រើនស្ដីអំពីនីតិវិធីព្រហ្មទណ្ឌបារាំងដូចមានក្នុងឯកសារយោងស្រាប់។ ដូចគ្នានេះដែរ នៅក្នុងសៀវភៅស្ដីអំពី "នីតិវិធីព្រហ្មទណ្ឌ" អ្នកនិពន្ធ Serge Guinchard និង Jacques Buisson ដែលជាអ្នកជំនាញខាងនីតិវិធីព្រហ្មទណ្ឌ [4] ក្រោយពីបានលើកឡើងថា យោងលើបទបញ្ញត្តិរួមនៃមាត្រា៣១ មាត្រា៤០ កថាខណ្ឌ១ និងមាត្រា៤១ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលថាមានតែព្រះរាជអាជ្ញាមួយគត់ដែលជាម្ចាស់នៃបណ្ដឹងអាជ្ញា គាត់ទាំងពីរនាក់បានធ្វើសេចក្ដីសន្និដ្ឋានថា: "*អ្វីមួយដែលជាភាពសមហេតុសមផលនៃច្បាប់នីតិវិធីរបស់យើង គឺថានៅពេលអង្គសវនាការ អ្នកដែលមានយោបល់ក្រោយដើមបណ្ដឹងរដ្ឋប្បវេណី គឺតំណាងអយ្យការ ហើយតំណាងអយ្យការជាអ្នកដែលស្នើសុំឲ្យមានការដាក់ទោសទៅលើជនល្មើស ដោយហេតុថាការដាក់ទោសនេះជាកម្មវត្ថុនៃបណ្ដឹងអាជ្ញា ហើយ**ដើមបណ្ដឹងរដ្ឋប្បវេណីមិនអាច និងមិនត្រូវ***

[3] សូមពិនិត្យមើល"*ចម្លើយតបរបស់ក្រុមមេធាវីការពារទៅនឹងបញ្ជីឈ្មោះសាក្សី និងឯកសារដែលដាក់ដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ១*" ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩ (E28/1 និង E28/2) កថាខណ្ឌទី៩ ដល់ទី ១៥។

[4] " នីតិវិធីព្រហ្មទណ្ឌ" Serge Guinchard et Jacques Buisson, Editions Litec, édition 2005, para.912.

***អនុវត្តសិទ្ធិនេះឡើយ*** ”។ មេធាវីការពារក្តីយល់ឃើញថា សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ និងក្រុម ៤ ដែលបានយល់ច្បាស់ពីគោលការណ៍គ្រឹះនៃនីតិព្រហ្មទណ្ឌ [5] មួយនេះ មិនបានចូលរួមក្នុងការធ្វើសំណើសុំដែលលើកឡើងដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ និងក្រុម ២ ទេ។

៦. ជាទីបញ្ចប់ ក្រុមមេធាវីការពារក្តីបានធ្វើការកត់សម្គាល់ឃើញថា តាមរយៈសេចក្តីសម្រេចចុះថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើករណីនេះ ពីព្រោះថាអង្គជំនុំជម្រះបានសម្រេចបដិសេធសំណើសុំរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ដែលប៉ុនប៉ងសុំឲ្យមានការកោះហៅសាក្សីចំនួនពីររូបទៀត ដែលពួកគេយល់ឃើញថាសាក្សីទាំងពីរនាក់នេះអាចជួយរួមចំណែកដល់អង្គជំនុំជម្រះនៅក្នុងការកំណត់អំពីទោសដែលត្រូវផ្តន្ទាទៅលើជនជាប់ចោទ។[6]

## ហេតុដូច្នេះ

៧. ក្រុមមេធាវីការពារក្តីសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូងមេត្តា:

- ប្រកាស និងសម្រេចថាភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតិឲ្យធ្វើកំណត់សម្គាល់ណាមួយដែលពាក់ព័ន្ធជាមួយនឹងការដាក់ទោសឡើយ និង
- បដិសេធចោលនូវសំណើសុំរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ និង ២។

---

[5] សូមពិនិត្យមើលឯកសារប្រតិចារិកនៃសវនាការជាសាធារណៈ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩, E1/4.1, ទំព័រ ១១ ដល់ ១៣។ សូមពិនិត្យមើលឯកសារប្រតិចារិកនៃសវនាការជាសាធារណៈ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩, E1/33.1, ទំព័រ ១១ បន្ទាត់ទី១៩ និងបន្តបន្ទាប់។

[6] សូមពិនិត្យមើល “សេចក្តីសម្រេចពាក់ព័ន្ធនឹងវិធានការណ៍ការពារដែលត្រូវបានស្នើចំពោះសាក្សី និងអ្នកជំនាញមួយចំនួន និងសំណើសុំរបស់គូរភាគីដែលស្នើឲ្យមានការកោះហៅសាក្សីនិងអ្នកជំនាញ – អំណះអំណាង” អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៣ មេសា ២០០៩ (E40/1)។ សូមពិនិត្យមើលកថាខណ្ឌទី ១៥ និង ២៣ នៃសេចក្តីសម្រេចនេះ។

E72/2

[001/18-07-2007-អវតក/អជសដ]

# សុំរក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

| | | |
|---|---|---|
| សហមេធាវីទាំងពីរ<br><br>មេធាវី **ការ សាវុត្ថ**<br><br>មេធាវី **Marie-Paule CANIZARES** | ភ្នំពេញ | |
| ឈ្មោះ | ទីកន្លែង | ហត្ថលេខា |